ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ...១៤៥/១៩......រ.ប.ក

# របាយការណ៍បូកសរុប

## សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខែមិថុនា និងទិសដៅខែកក្កដា ឆ្នាំ២០១៩

## I. ស្ថានភាពទូទៅ

ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាប ជាបន្តបន្ទាប់ ដោយមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័ន ជាសមាជិក គ.ជ.ប.ជ និងអង្គភាពពាក់ព័ន្ធនានា រួមទាំងលេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ)។ ក្រោយពីរាជរដ្ឋាភិបាលថៃ បានផ្តល់ភាពស្របច្បាប់ដល់ពលករប្រមាណ ជាងមួយលានប្រាំមួយម៉ឺននាក់ ហើយក៏ដោយ ក៏ការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍មិនប្រក្រតីក៏នៅតែមានដដែល ពលរដ្ឋខ្មែរនៅតែបាន និងកំពុងចូលទៅធ្វើការនៅប្រទេសថៃ ដោយខុសច្បាប់ជាបន្តទៅទៀត ទោះបីត្រូវជួបប្រទះបញ្ហាប្រឈម ហានីភ័យនានា ដូចជា ការបញ្ជូនត្រឡប់មកវិញ ការឃាត់ខ្លួន ការដាក់ទោសទណ្ឌ ពីអាជ្ញាធរប្រទេសថៃ រងការកេងប្រវ័ញ្ច ខាតបង់ប្រាក់កាស និងពេលវេលា ជាដើម។ល។ ប្រជាពលរដ្ឋមួយចំនួន នៅតែចាញ់ឧបាយកលមេខ្យល់បោកប្រាស់ ដែលប្រើរូបភាពជាភ្នាក់ងារមានសមត្ថកិច្ច ផ្តល់ឯកសារក្លែងក្លាយជាអ្នករត់ការផ្តល់ភាពស្របច្បាប់ ហើយទាមទារកម្រៃខ្ពស់ពីពលករ ឬជាអ្នកជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនទៅរកការងារក្រៅប្រទេស មានប្រាក់ខែច្រើន។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព ដៃគូជាតិ និងអន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចសហប្រតិបត្តិការក្នុងការដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការងារបទដ្ឋានច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងឯកសារកិច្ចសហប្រតិបត្តិការកំពុងរៀបចំ និងដំណើរការ

ក.១.១. អនុស្សរណៈនៃការយោគយល់គ្នាដែលបានចុះហត្ថលេខារួច

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)
  - -អនុស្សរណៈនៃការយោគយល់គ្នារវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការឆាលហ្វាន កម្ពុជា ស្តីពី "សហគមន៍កុមារមេត្រី ប្រឆាំងនឹងការជួញដូរកុមារ និងធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព" នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩។

ក.១.២. គោលនយោបាយកំពុងរៀបចំ

- ក្រសួងអប់រំ យុវជន និងកីឡា៖ កំពុងធ្វើសេចក្ដីព្រាងគោលនយោបាយ ស្ដីពី "**កិច្ចការការពារកុមារតាមសាលារៀន**"។

ក.១.៣. សេចក្ដីព្រាងច្បាប់កំពុងរៀបចំ

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្ដីព្រាងច្បាប់ ស្ដីពី"**ការពពោះជំនួស**"។
- ក្រសួងយុត្តិធម៌ បានរៀបចំសេចក្ដីព្រាងច្បាប់៖
  - ស្ដីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" (MLA)
  - ស្ដីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

ក.១.៤. សន្ធិសញ្ញាកំពុងរៀបចំ

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្ដីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្ដីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**"
  - បានកំពុងរៀបចំសេចក្ដីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្ដីពី "ការបញ្ជូនទណ្ឌិត"។

ក.១.៥. អនុស្សរណៈកំពុងរៀបចំ

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International។
- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រីលើកទី២ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃប្រទេសម៉ាឡេស៊ី ស្ដីពី "**ការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី**"។

ក.១.៦. បទដ្ឋានគតិយុត្តកំពុងរៀបចំ

- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ៖ ធ្វើសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្តិ "**សម្រាប់អនុវត្តលក្ខខណ្ឌការងារកម្មករការងារផ្ទះ**"។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្ដីព្រាងរៀបចំអនុក្រឹត្យ ស្ដីពីបែបបទគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ខ. ការបង្ការ ទប់ស្កាត់

### ខ.១. ការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង

ខ.១.១. ការផ្សព្វផ្សាយដោយផ្ទាល់

ខ.១.១.១. ការផ្សព្វផ្សាយតាមរយៈវេទិកា និងកម្មវិធីផ្សេងៗ

នៅក្នុងខែមិថុនា ឆ្នាំ២០១៩នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋបាន សរុបចំនួន **៥.៩៦៩**លើក មានអ្នកចូលរួមសរុបចំនួន **២៩៧.៨៩៣**នាក់ (ស្រី **១៦៣.៣៦២**នាក់) ក្នុងនោះមាន៖

តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ១៣៥ | ៥.៩១៤ | ៣.៥៨៤ | | | |
| សរុប ក្រសួង ស្ថាប័ន | | ១៣៥ លើក | ៥.៩១៤ នាក់ | ៣.៥៨៤ នាក់ | | | |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្ដាល | ៤៩ | ៤.១៩៦ | ២.២៧៦ | ៩៦ | ២.៨៦១ | ១.៣៨០ |
| ៣ | ខេត្តបាត់ដំបង | ១.២៣៣ | ៥៤.៤១១ | ២៨.៨៣៨ | ៤០៩ | ១៥.៣១៣ | ៨.០២០ |
| ៤ | ខេត្តពោធិ៍សាត់ | ៤០៣ | ៤១.៥០៧ | ២២.១១៩ | ១២៨ | ៤.៦៧០ | ២.៥១១ |
| ៥ | ខេត្តសៀមរាប | ៤៤៦ | ២៥.៩៥៥ | ១៥.៩៣៥ | ៨១ | ៣.២៧០ | ១.៩២៩ |
| ៦ | ខេត្តកំពង់ឆ្នាំង | ១.០២៤ | ៥១.៨៤៨ | ២៩.៣០៩ | ៥៥៧ | ២១.៩៨៧ | ១២.៣១៦ |
| ៧ | ខេត្តកំពង់ចាម | ៣៣១ | ១៧.៦០១ | ៩.៩៩៥ | ២៥៨ | ៨.១៩៤ | ៥.៤៥១ |
| ៨ | ខេត្តព្រះសីហនុ | ៤៧ | ៧៥៦ | ៣៦០ | ៤៤ | ៥៩៩ | ៣១៣ |
| ៩ | ខេត្តព្រះវិហារ | ៤ | ៦៣២ | ៣៨០ | ២ | ៦២ | ៤២ |
| ១០ | ខេត្តស្វាយរៀង | ៨ | ៣៣ | ១៧ | ៣៥២ | ១៣.៨៤១ | ៦.៥២៩ |
| ១១ | ខេត្តប៉ៃលិន | ៣០ | ៤.២៨៥ | ១.៩០៨ | ២២ | ១.៥៣២ | ៩៣២ |
| ១២ | ខេត្តកោះកុង | | | | | | |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | ១ | ២១៥ | ១១៦ | | | |
| ១៥ | ខេត្តតាកែវ | ១៩៧ | ៨.៤៨៧ | ៤.២៣២ | ៣៥ | ១.១៥៦ | ៥៣៨ |
| ១៦ | ខេត្តក្រចេះ | | | | | | |
| ១៧ | ខេត្តកែប | | | | ៣៦ | ៥.៧៨៥ | ២.៦០៣ |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | ១ | ៣០០ | ០ | | | |
| ២២ | ខេត្តត្បូងឃ្មុំ | | | | ៤ | ១៨១ | ១៣៣ |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | ៣៦ | ២.៣០២ | ១.៥៣៣ | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| សរុប រាជធានី-ខេត្ត | | ៣.៨១០លើក | ២១២.៥២៨ នាក់ | ១១៧.០៨១ នាក់ | ២.០២៤ លើក | ៧៩.៤៥១ នាក់ | ៤២.៦៩៧ នាក់ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន ៥.៩៦៩ លើក | | ចំនួនអ្នកចូលរួម ២៩៧.៨៩៣ នាក់ | | ចំនួនស្ត្រី ១៦៣.៣៦២ នាក់ | |

### ខ.១.២. ការផ្សព្វផ្សាយតាមរយៈឧបករណ៍ ប្រព័ន្ធផ្សព្វផ្សាយ និងការចូលរួមជាវ៉ាក្លីន

#### ខ.១.២.១. ការផ្សព្វផ្សាយតាមរយៈឧបករណ៍ផ្សព្វផ្សាយ និងតាមប្រព័ន្ធផ្សព្វផ្សាយ

- ខេត្តសៀមរាបៈ មន្ទីរព័ត៌មានខេត្ត បានសហការជាមួយអង្គភាព អាជ្ញាធរ និងអង្គការពាក់ព័ន្ធ ធ្វើកម្មវិធី "យើងធ្វើបាន" និង "សន្ទនាមតិ" បានសរុបចំនួន ២៨លើក (ផ្សាយផ្ទាល់ ០៨លើក ចាក់ផ្សាយឡើងវិញ ២០លើក) ។

- ខេត្តតាកែវៈ ផ្សព្វផ្សាយព័ត៌មាន និងច្បាប់ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចំនួន ៤អត្ថបទ និង ៣៨លើក។
- ខេត្តកំពង់ចាមៈ ផ្សព្វផ្សាយតាមរឿងអប់រំខ្លីៗពាក់ព័ន្ធចំណាកស្រុកដោយសុវត្ថិភាព ចំនួន ១២លើក។

ខ.១.២.២. ការចូលរួមជាវាគ្មិន

- ខេត្តក្រចេះៈ បានចូលរួមជាវាគ្មិនក្នុងកម្មវិធីបញ្ឈប់អំពើហឹង្សាលើស្ត្រី និងកុមារ ក្រោមប្រធានបទ អំពើហិង្សា និងការរំលោភសេពសន្ថវៈលើស្ត្រី និងក្មេងស្រី តាមរយៈការផ្សាយសម្លេង និងឡាយតាមហ្វេសបុក របស់វិទ្យុសម្លេងស្ត្រីខេត្តក្រចេះ ចំនួន ០១លើក។
- ខេត្តកំពង់ចាមៈ ស្នងការដ្ឋាននគរបាល និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ លើប្រធានបទ អំពើជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ ជាមួយបុរសជនជាតិចិន។

## ខ.២. ការបង្ការ ទប់ស្កាត់ តាមរយៈវិធានការជំនាញ

### ខ.២.១. វិធានការជំនាញទប់ស្កាត់ការធ្វើទេសន្តរប្រវេសន៍ (ចំណាកស្រុក)

ខ.២.១.១. ការគ្រប់គ្រងជនបរទេស

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍**

១. ការងារអនុវត្តនីតិវិធី និងការបណ្តេញចេញជនបរទេសខុសច្បាប់: ជនបរទេសដែលល្មើសច្បាប់ស្តីពីអន្តោប្រវេសន៍ ត្រូវបានបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា សរុបចំនួន **១១៣**លើក មនុស្សចំនួន **១៧១**នាក់(ស្រី **១៩**នាក់) មាន ៤២សញ្ជាតិ ក្នុងនោះត្រូវបានបណ្តេញចេញដោយប្រកាសក្រសួងមហាផ្ទៃ **២៦**លើក មនុស្សចំនួន **៣៧**នាក់ (ស្រី **០៧**នាក់) មាន **១០**សញ្ជាតិ។

២. ការបដិសេធមិនឱ្យចូលប្រទេស:
បដិសេធជនបរទេសមិនឲ្យចូលប្រទេស តាមប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិនានា **៨៧**លើក មនុស្សចំនួន **១៣៦**នាក់ មាន ៣០សញ្ជាតិ។

៣. ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី
ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ពីជនបរទេសបែបអន្តោប្រវេសន៍ បានចំនួន **២៥៩** ឯកសារ សរុបមនុស្សចំនួន **២១៦**នាក់(ស្រី**១០៨**នាក់) **១១៤**គ្រួសារ សញ្ជាតិវៀតណាម។

ខ.២.១.២.ការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានធ្វើបច្ចុប្បន្នភាពទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស សរុបចំនួន **៣៦០.៤៤២**នាក់ (ស្រី **១៥៧.៦៤៥**នាក់) អនីតិជន **៦.៩១៤**នាក់ (ស្រី **២.៧១៤**នាក់) ក្នុងនោះស្របច្បាប់ចំនួន **២១៩.១៤៣**នាក់ (ស្រី **៩៣.៨១២**នាក់) អនីតិជន **៦៥៧**នាក់ (ស្រី **២៧៨**នាក់) មិនស្របច្បាប់ចំនួន ១៤១.២៩៩នាក់ (ស្រី **៦៣.៨៣៣**នាក់) អនីតិជន **៦.២៥៧**នាក់ (ស្រី **២.៤៣៦**នាក់) បើប្រៀបធៀបនឹងខែឧសភាមានការកើនឡើងចំនួន ៨.៥៣៧នាក់ ស្មើ ២,៤២%។

- **ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបងៈ** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរៈសេនាតូចការពារព្រំដែនគោកលេខ ៨១៧ ៨១៩ ៨២៣ និង៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែនដើម្បីទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់ ចំនួន **៦០**លើក ពុំប្រទះឃើញពលករឆ្លងដែនខុសច្បាប់ទេ។

**ខ.២.២. វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ**

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ

- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពទិន្នន័យគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ សរុបចំនួន **៧៥**គោលដៅ ក្នុងនោះអំពើជួញដូរមនុស្សចំនួន ០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន **៦៦**គោលដៅ។
- **ស្នងការដ្ឋាននគរបាលខេត្ត** ធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ស្ត្រីក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន **២៨០**គោលដៅ និងមានមនុស្សចំនួន **១.១៥២**នាក់ (ស្រី **៩៥០**នាក់) នៅខេត្តតាកែវ មណ្ឌលគិរី កែប និងខេត្តកោះកុង។
- **ស្នងការដ្ឋាននគរបាលខេត្ត** ល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន **៣៤**លើក នៅខេត្តស្វាយរៀង តាកែវ ព្រះវិហារ កំពង់ស្ពឺ ស្ទឹងត្រែង និងខេត្តពោធិ៍សាត់។

**ខ.២.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

▪ ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) នៃច្រកចេញចូលតែមួយ របស់ក្រសួងមហាផ្ទៃទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស សរុបចំនួន **១៥១**គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងទៅនារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីនៅក្រៅប្រទេស តាមរយៈទូរស័ព្ទផ្ទាល់ ចំនួន **១៦**នាក់ ដើម្បីតាមដានស្ថានភាព ដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្ស តាមរយៈការរៀបអាពាហ៍ពិពាហ៍។

## ខ.៣. កិច្ចការពារកុមារ

- **ខេត្តក្រចេះ៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះត្រួតពិនិត្យមណ្ឌលអង្គការដំណឹងល្អទាំង៤ លើការថែទាំជំនួសចំពោះកុមារក្នុងខេត្ត ចំនួន ២១នាក់ (កុមារី ០៨នាក់)។
- **ខេត្តកំពង់ធំ៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះត្រួតពិនិត្យក្រុមប្រឹក្សាយុវជន និងក្រុមប្រឹក្សាកុមារ ចំនួន ០៥លើក ១២សាលារៀន ដែលមានយុវជន និងកុមារចូលរួមសរុប ២៥៧ នាក់ (ស្រី ១៣៦នាក់)។
- **ខេត្តព្រះសីហនុ៖**

សហការជាមួយអង្គការម្លប់តាប៉ាង បានដាក់បណ្តាញម៉ូតូឌុប និងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍ ចំនួន **១.១៣៣**នាក់។

- **ខេត្តប៉ៃលិន៖**

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ច ដើម្បីទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសែឡូ កាស៊ីណូ ឡតដ្ឋ ភោជនីយដ្ឋាន និងអាហារដ្ឋាន ចំនួន ៨០កន្លែង។

### ខ.៤. ការកាត់បន្ថយភាពងាយរងគ្រោះ តាមរយៈការផ្ដល់ប័ណ្ណព្រំដែនដល់មុខសញ្ញារងគ្រោះ

- រដ្ឋបាលខេត្តចំនួន០៣ គឺខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានផ្ដល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ (Border Pass) សរុបចំនួន ៣.៦៦២ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន មានៈ
  - ខេត្តបាត់ដំបង ចំនួន ៣.០៦៣ប័ណ្ណ
  - ខេត្តបន្ទាយមានជ័យ ចំនួន ០០ប័ណ្ណ
  - ខេត្តប៉ៃលិន ចំនួន ៥៩៩ប័ណ្ណ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ កងរាជអាវុធហត្ថ ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ក្រចេះ កំពង់ចាម កំពង់ឆ្នាំង និងខេត្តសៀមរាប។

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួន ០៩ករណីលើ១៦ករណី (បើប្រៀបធៀបនឹងខែឧសភា គឺមានការថយចុះចំនួន ០៧ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ០៩នាក់(ស្រី ០៤នាក់ អនីតិជន ០១នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ២១នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ១៣នាក់ អាយុ១៥-១៧ឆ្នាំ ០៥នាក់ និងអាយុ១៨ឆ្នាំឡើង ០៣នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ១៦នាក់ និងប្រគល់ទៅគ្រួសារ ០៥នាក់) ក្នុងនោះមានៈ

##### គ.១.១.១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០៤ករណីលើ០៣ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ០៤នាក់(ស្រី ០៣នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ១០នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ០៨នាក់ អាយុ១៥-១៧ឆ្នាំ ០២នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ០៩នាក់ ប្រគល់ទៅគ្រួសារ០១នាក់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោមៈ

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០១ | ០១ | ០១ |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០១ | ០២ | ០១ |
| -ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០១ | ០៥ | ០១ |
| -អំពើលក់ដូរមនុស្ស | ០១ | ០២ | ០១ |
| *សរុប* | *០៤ ករណី* | *១០ នាក់* | *០៤ នាក់* |

##### គ.១.១.២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ០៥ករណីលើ១៣ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ០៥នាក់(ស្រី ០១នាក់ អនីតិជន ០១នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ១១នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ០៥នាក់ អាយុ១៥-១៧ឆ្នាំ០៣នាក់ និងអាយុ១៨ឆ្នាំឡើង ០៣នាក់(ប្រគល់ទៅមន្ទីរសង្គមកិច្ច ០៧នាក់ និងប្រគល់ទៅគ្រួសារ ០៤នាក់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោមៈ

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -សញ្ញារកម្ម(មានអនីតិជន) | ០១ | ០៧ | ០១ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៣ | ០៣ | ០៣ (អនី.១) | |
| -អំពើអាសប្រទាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១ | ០១ | ០១ | |
| *សរុប* | *០៥ ករណី* | *១១នាក់* | *០៥ នាក់* | *គ្មាន* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

  យោងស្ថិតិ **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** បានទទួលពលរដ្ឋខ្មែរសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស សរុបចំនួន **២.៩១៤**នាក់ (ស្រី **១.១៧១**នាក់) អនីតិជន **១៦៦**នាក់ ក្នុងនោះមកពី៖

  - ប្រទេសថៃ ចំនួន **២.៩០៣**នាក់ (ស្រី **១.១៦៦**នាក់) អនីតិជន **១៦៦**នាក់
  - ប្រទេសវៀតណាម ចំនួន **០១**នាក់ (ស្រី **០១**នាក់)
  - ប្រទេសចិន ចំនួន **០៨**នាក់ (ស្រី **០២**នាក់)
  - ប្រទេសម៉ាឡេស៊ី ចំនួន **០២**នាក់ (ស្រី **០២**នាក់)។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)**

  ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការងារការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការចាប់ដៃ និងអង្គការអាដហុក បានទទួលជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសនានាតាមច្រកព្រលានយន្តហោះ សរុបចំនួន **០៩**នាក់(ស្ត្រី **០៧**នាក់ កុមារី **០២**នាក់) មកពី៖ ប្រទេសចិន ០៥នាក់ វៀតណាម(ឆ្លងទៅចិន) ០២នាក់ អារ៉ាប៊ីសាអូឌីត ០២នាក់ (ករណីអាពាហ៍ពិពាហ៍ក្លែងក្លាយ ០៧នាក់ និងជួញដូរកម្លាំងពលកម្ម ០២នាក់)។

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

  នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួល និងសម្ភាសពលករខ្មែររងគ្រោះចំនួន **០៥**នាក់(ស្រី **០៥**នាក់) ដែលត្រឡប់ពីប្រទេសចិន។ តាមការសម្ភាសបានឲ្យដឹងថា អ្នកទាំងនោះទៅតាមរយៈមេខ្យល់។

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍**

  បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន **១០១**លើក មនុស្សចំនួន **១.៣៩៣**នាក់(ស្រី **៤០៨**នាក់ កុមារ **១២៤**នាក់) ក្នុងនោះតាម៖

  - ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ **២៧**លើក មនុស្សចំនួន **៦៣**នាក់ (ស្រី **២៦**នាក់)
  - ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ **៧៤**លើក មនុស្សចំនួន **១.៣៣០**នាក់ (ស្រី **៣៨២**នាក់ កុមារ **១២៤**នាក់)។

- **អគ្គបញ្ជាការដ្ឋាន ទីចាត់ការការងារព្រំដែន**

បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ សរុបចំនួន **១.២៣៩**នាក់( ស្រី **៣៧៤**នាក់ អនីតិជន **១៤២**នាក់ ) ក្នុងនោះមានៈ

- ច្រកអន្តរជាតិប៉ោយប៉ែត ចំនួន **១.១២៥**នាក់ ( ស្រី **៣៣៦**នាក់ ) អនីតិជន **១៣៨**នាក់
- ច្រកអន្តរជាតិដូង ចំនួន **១១៤**នាក់ ( ស្រី **៣៨**នាក់ ) អនីតិជន **០៤**នាក់។

- **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត**

**ស្នងការដ្ឋាននគរបាលខេត្ត ចំនួន៣** បានទទួល និងសម្ភាសន៍ពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ សរុបចំនួន **១.២០២**នាក់ ( ស្រី **៣៥៧**នាក់ អនីតិជន **១១០**នាក់ ) ក្នុងនោះមានៈ

- **ខេត្តបន្ទាយមានជ័យ** ចំនួន **១.០៨៣**នាក់ (ស្រី**៣១៥**នាក់) អនីតិជន **១០៧**នាក់
- **ខេត្តបាត់ដំបង** ចំនួន **១០២**នាក់ ( ស្រី **៣៨**នាក់ ) អនីតិជន **០៣**នាក់
- **ខេត្តកោះកុង** ចំនួន **១៧**នាក់ ( ស្រី **០៤**នាក់ )។

### **ឃ.១.២. ការទទួលសាកសពបញ្ជូនត្រឡប់**

- **អគ្គបញ្ជាការដ្ឋាន ទីចាត់ការការងារព្រំដែន**

បានទទួលសាកសពដែលអាជ្ញាធរថៃបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែនអន្តរជាតិដូង ចំនួន **១៣**សព ( ស្រី **០៣** )។

## **ឃ.២. ការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (**ក្រុមការងារការពារជនរងគ្រោះ**) និងមន្ទីរសង្គមកិច្ច រាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិសម្បទា ចំនួន **៦០**នាក់( ស្ត្រី **៤៧**នាក់ កុមារ **១៣**នាក់ ) រួមមានៈ

- មជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានផ្តល់សេវាស្នាក់នៅរយៈពេលខ្លី និងការស្តារនីតិសម្បទា ដល់ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន **១៥**នាក់( ស្ត្រី **០២**នាក់ កុមារ **១៣**នាក់ ) និងបានបញ្ជូនទៅអង្គការសាម៉ារីតាន់ភីស ដើម្បីទទួលសេវាអប់រំក្នុង និងក្រៅប្រព័ន្ធ និងសេវាផ្សេងៗទៀតមុនពេលធ្វើសមាហរណកម្មត្រឡប់ទៅផ្ទះវិញ។
- មន្ទីរស.អ.យ រាជធានី ខេត្ត បានសង្គ្រោះ ទទួល និងផ្តល់សេវាពិគ្រោះយោបល់ និងបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន **៤៤**នាក់( ស្រី ) ទៅទទួលសេវានៅមន្ទីរ ស.អ.យ ភ្នំពេញ ០៧នាក់( ករណីអាជីវកម្មផ្លូវភេទ ) ពោធិ៍សាត់ ០១នាក់( ករណីរំលោភ ) ស្វាយរៀង ១៥នាក់( ករណីជួញដូរកម្លាំងពលកម្ម ) ក្រចេះ ០៤នាក់( ករណីជួញដូរមនុស្ស ) និងមន្ទីរ ស.អ.យ ខេត្តសៀមរាប ១៧នាក់( ករណីងាយរងគ្រោះ )។
- បានធ្វើការសម្ភាស ពិគ្រោះយោបល់ និងបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន **០១**នាក់( ស្រី ) ទៅទទួលសេវាបន្តនៅអង្គការក្តីសង្ឃឹម និងយុត្តិធម៌។

#### ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងខាយរងគ្រោះ

- បានធ្វើសមាហរណកម្មស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រឡប់ទៅសហគមន៍វិញចំនួន ០៤នាក់ ករណីរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ០២នាក់ និងជួញដូរកម្លាំងពលកម្ម ០២នាក់។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការងារបណ្តុះបណ្តាល

##### ក.១.១.ការបណ្តុះបណ្តាលក្នុងប្រទេស

តារាងវគ្គបណ្តុះបណ្តាល

| សកម្មភាព | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន៖**<br>- សហការជាមួយអង្គការ CPU បើកវគ្គបណ្តុះបណ្តាល ស្តីពីការស៊ើបអង្កេតបទល្មើសរំលោភបំពានលើកុមារ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស | ០១ | ៥៦ | ២២ |
| **ខេត្តកំពង់ឆ្នាំង៖**<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីបង្គោល ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ០១ | ១០៥ | ៤៥ |
| **ខេត្តសៀមរាប៖**<br>- បើកវគ្គបណ្តុះបណ្តាលស្តីពី កិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត និងសុវត្ថិភាពក្នុងការប្រើប្រាស់អ៊ីនធឺណិត និងកិច្ចបង្ការការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងសហគមន៍ | ០៤ | ១៧០ | ៨៧ |
| **ខេត្តព្រះវិហារ៖**<br>- ស្នងការដ្ឋាននគរបាលខេត្ត សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ បើកវគ្គបណ្តុះបណ្តាលហ្វឹកហ្វឺនស្តីពី នីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស និងក្រមសីលធម៌ ក្នុងការសម្ភាសន៍កំណត់អត្តសញ្ញាណជនរងគ្រោះ | ០១ | ៣០ | ០៦ |
| **ខេត្តព្រះសីហនុ៖**<br>- ស្នងការដ្ឋាននគរបាលខេត្ត សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ បើកវគ្គបណ្តុះបណ្តាលស្តីពី ការពង្រឹងសមត្ថភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅស្រុកស្ទឹងហាវ ស្រុកព្រៃនប់ និងស្រុកកំពង់សិលា។ | ០៣ | ១៥៧ | ៤៧ |
| **សរុប** | **១០ វគ្គ** | **៥១៨ នាក់** | **២០៧ នាក់** |

#### ក.២. សិក្ខាសាលា

##### ក.២.១.សិក្ខាសាលាក្នុងប្រទេស

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ)**

  បានរៀបចំសិក្ខាសាលា លើគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដែលមានសិក្ខាកាមចូលរួមចំនួន **៦៩**នាក់(ស្រី **២៧**នាក់)។

- **អគ្គស្នងការដ្ឋាននគរបាលជាតិ(ក្រុមការងារអនុវត្តច្បាប់)**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយអង្គការ APLE បើកសិក្ខាសាលាស្តីពី កិច្ចសហប្រតិបត្តិការពហុស្ថាប័នក្នុងការការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទក្នុងវិស័យទេសចរណ៍ នៅភោជនីយដ្ឋានទន្លេបាសាក់១ ភ្នំពេញ មានសិក្ខាកាមចំនួន៦៥នាក់(ស្ត្រី៣២នាក់)។

- **ខេត្តកោះកុង៖**

មន្ទីរទេសចរណ៍ខេត្ត រៀបចំសិក្ខាសាលាស្តីពី ការយល់ដឹងអំពីការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទលើកុមារ ក្នុងវិស័យទេសចរណ៍ នៅឃុំប៉ាក់ខ្លង មានសិក្ខាកាមចំនួន ២៧នាក់(ស្ត្រី១១នាក់)។

## ២. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ២.១ កិច្ចប្រជុំ ជាអន្តរជាតិនៅក្នុងប្រទេស និងក្រៅប្រទេស

➢ **កិច្ចប្រជុំក្នុងប្រទេសជាលក្ខណៈអន្តរជាតិ**

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)

លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំប្រតិភូអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីទៅចូលរួមក្នុងកិច្ចប្រជុំ ស្តីពីការផ្សព្វផ្សាយសកម្មភាពថ្មីក្នុងការរួមគ្នាប្រឆាំងអំពើទាសភាពសម័យទំនើប ក្នុងសង្វាក់ផលិតកម្ម ដែលធ្វើឡើងនៅក្នុងប្រទេសអូស្ត្រាលី ដែលមានសមាសភាពចូលរួមប្រមាណជាង ៤០០នាក់ មកពីបណ្តា ២០ ប្រទេសផ្សេងគ្នាជុំវិញពិភពលោក។

➢ **កិច្ចប្រជុំក្នុងប្រទេស**

- **កិច្ចប្រជុំពិភាក្សាអន្តរក្រសួង**
  - ពិភាក្សា សម្រេចលើផែនការសកម្មភាពជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ៥ឆ្នាំ (២០១៩-២០២៣) អ្នកចូលរួម **៦១**នាក់ (ស្រី **១៧**នាក់) នៅទីស្តីការក្រសួងមហាផ្ទៃ អគារ ៥ ។
  - លើនីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពី ការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម ជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ អ្នកចូលរួមចំនួន **១៩**នាក់ (ស្រី ០៨នាក់) នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
  - ពិនិត្យ សម្រេច និងផ្តល់ជាតុចូលបន្ថែម ទាក់ទងនឹងការអនុវត្តសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៧២/១៩៥ ស្តីពី ការធ្វើឲ្យប្រសើរឡើងនូវកិច្ចប្រឹងប្រែង អ្នកចូលរួមចំនួន **២៥**នាក់ (ស្រី ០៨នាក់) នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចំនួន **០២**លើក។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
  - បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យ និងពង្រឹងកិច្ចសហប្រតិបត្តិការស្តីពី ការការពារ និងគាំទ្រជនរងគ្រោះរវាងនាយកដ្ឋាន និងអង្គការដៃគូ នៅទីស្តីការក្រសួងស.អ.យ អ្នកចូលរួម ១០៦នាក់(ស្រី ៣២នាក់)។

### ២.២. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ **៥៩**លើក មានអ្នកចូលរួមសរុប **១.៨២៩**នាក់ (ស្រី **៨៥២**នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស **១៤**លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា **០៦**លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន **៣៩**លើក។ (**ឧបសម្ព័ន្ធ១**)

## III. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការផ្ញើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

### គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.ខ.ប.ជ/គ.រ.ប.ជ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ។

- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

**ឃ. សន្និដ្ឋាន**

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃ មន្ត្រីយើងកាន់តែយល់ដឹងកាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋ ដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## IV. ទិសដៅខែមិថុនា ឆ្នាំ ២០១៩

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួម ដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាព ជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "**គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី**" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.......................ខែ..........ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ..........ឆ្នាំ២០១៩

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ-ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"**ដើម្បីគោរពជូនជាសេចក្តីរាយការណ៍**"

- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារគ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"**ដើម្បីជូនជ្រាប**"

- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៥៩លើក) មនុស្សចំនួន ១.៨២៩នាក់ (ស្ត្រី ៨៥២នាក់)

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | សម្របសម្រួលចំនួន ១៤លើក អ្នកចូលរួមចំនួន ២០១នាក់ (ស្ត្រី ១៩នាក់)<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួមដឹកនាំកិច្ចប្រជុំ៖<br>○ ស្តីពីវេទិកាអន្តរសាសនាថ្នាក់ជាតិនៅកម្ពុជាលើកទី៣ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន ២១នាក់ ស្រី ០២នាក់។<br>○ ស្តីពីសេចក្តីព្រាងច្បាប់ នីតិវិធីស្តង់ដារ ប្រតិបត្តិ កិច្ចសហប្រតិបត្តិការ អនុវត្តច្បាប់ រវាងប្រទេសថៃ និង កម្ពុជា អ្នកចូលរួមចំនួន ១៩នាក់ ស្រី ០៨នាក់។<br>○ ពិភាក្សា ដើម្បីឆ្លើយតបសង្ខេបទៅនឹងផែនការ យុទ្ធសាស្ត្រ CEDAW ដែលមានចំណែកក្នុងការការពារស្ត្រី និងកុមារ ដែលការឆ្លើយតបនោះជាការឆ្លើយតបទៅនឹងយន្តការថ្នាក់ជាតិ ស្របតាម Recommendation របស់ CEDAW ។<br>○ ស្តីពីការផ្តល់ធាតុចូលលើការអនុវត្តសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ អ្នកចូលរួមចំនួន ១២នាក់ ស្រី ០១នាក់។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ១៧ច្បាប់ លិខិតចូល ០៨ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ១៧ច្បាប់ លិខិតចូល ០៩ច្បាប់។<br>- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែមិថុនា ឆ្នាំ២០១៩ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បូកសរុបរបាយការណ៍ខែមិថុនា ត្រីមាសទី២ និងឆមាសទី១ ឆ្នាំ២០១៩ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។<br>- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវិគី។<br>- ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។<br>- Scan & Uploaded ឯកសារចូលក្នុងបណ្ណាសារនៃប្រព័ន្ធ wiki បានចំនួន ០៨ច្បាប់។<br>- អាប់ឡូតរូបភាពសកម្មភាព គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធអ៊ិនធើណេត wiki បានចំនួន ២២សកម្មភាព។<br>▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់៖**<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ស៊ុន វ៉ូ** អគ្គលេខាធិការរង បានដឹកនាំលោកអនុប្រធានក្រុម និងមន្ត្រីជំនួយកិច្ចការ ដើម្បីចូលរួមជាគ្រូបង្គោល ធ្វើបទឧទ្ទេសនាមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព និងបោសសំអាតកាកសំណល់សង្គ្រាម។ |

| | |
|---|---|
| | - លោកប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានចូលរួមកិច្ចប្រជុំពិនិត្យសម្រេចទៅលើផែនការបង្ការ ទប់ស្កាត់ អន្តរក្រសួងស្ថាប័ន ដឹកនាំដោយលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ ក្រុមបង្ការ ទប់ស្កាត់ អ្នកចូលរួមចំនួន ២១នាក់ នៅទីស្តីការក្រសួងអប់រំ យុវជន និងកីឡា។<br>▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌៖**<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក **យឹម វិរៈ** បានអញ្ជើញចូលរួម៖<br>○ ក្នុងកម្មវិធីផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់សារអប់រំ ស្តីពីការការពារកុមារពីការរំលោភបំពាន និងបៀតបៀនផ្លូវភេទ ក្រោមអធិបតីភាពលោកជំទាវ ញ៉េប សុភាព អគ្គលេខាធិការ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ អ្នកចូលរួមចំនួន ៧០នាក់ នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>○ ប្រជុំក្រុមការងារបច្ចេកទេសនៃគណៈកម្មការការពារកុមារថ្នាក់ជាតិ ដើម្បីពិនិត្យលើសេចក្តីព្រាងគោលនយោបាយជាតិស្តីពីប្រព័ន្ធការពារកុមារ ក្រោមអធិបតីភាព លោកជំទាវ ញ៉េប សុភាព អគ្គលេខាធិការ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ អ្នកចូលរួមចំនួន ៣០នាក់ នៅភោជនីយដ្ឋានទន្លេបាសាក់២។<br>○ សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាង នៃការវិភាគស្ថានភាពដំបូង នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអ៊ីនធើណែតនៅកម្ពុជា ក្រោមអធិបតីភាព លោកជំទាវ ញ៉េប សុភាព អគ្គលេខាធិការ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ អ្នកចូលរួមចំនួន ២៨នាក់ ស្រី ០៨នាក់ នៅសណ្ឋាគារតាតៃ ខេត្តកោះកុង។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ៖**<br>- លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា** បានអញ្ជើញចូលរួម៖<br>○ កិច្ចប្រជុំ ស្តីពីសិទ្ធិមនុស្ស សិទ្ធិនយោបាយ និងបរិស្ថានសង្គមស៊ីវិល នៅក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។<br>○ កិច្ចប្រជុំពិភាក្សា និងត្រៀមរៀបចំរបាយការណ៍ឆ្លើយតបទៅនឹងបញ្ហាបញ្ហា និងសំណួរទាក់ទងទៅនឹង របាយការណ៍តាមកាលកំណត់លើកទី៦ របស់ប្រទេសកម្ពុជា (List of issues and questions) ដែលផ្តល់ដោយគណៈកម្មាធិការ CEDAW នៃអង្គការសហប្រជាជាតិ នៅភោជនីយដ្ឋានអ័រគីដេ។<br>○ មន្ត្រីក្រុមជំនួយកិច្ចការបានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា ឥណ្ឌា លើកទី២ នៅទីក្រុងញូវដែលី ប្រទេសឥណ្ឌា ដោយធ្វើការផ្តល់របាយការណ៍វឌ្ឍនភាព(រួមទាំងបញ្ហាប្រឈម និងទិសដៅអនាគត) ក្រោមអធិបតីភាពលោកជំទាវ អ៊ិត សោភា រដ្ឋលេខាធិការ នៅទីស្តីការក្រសួងការបរទេស។<br>○ មន្ត្រីក្រុមជំនួយកិច្ចការបានចូលរួមកិច្ចប្រជុំ ស្តីពីការងារពាក់ព័ន្ធរបាយការណ៍ត្រីមាសទី២ ឆ្នាំ២០១៩ និងការងារកែសម្រួល Commit MOU ក្រោមអធិបតីភាព លោកជំទាវ ហ៊ូ សាមិត្ត រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងជាប្រធានក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៅទីស្តីការក្រសួងកិច្ចការនារី។ |
| ក្រសួងសង្គមកិច្ច<br>អតីតយុទ្ធជន<br>និងយុវនីតិសម្បទា | - បានចូលរួមជាគ្រូឧទ្ទេស ក្នុងវគ្គបណ្តុះបណ្តាលរបស់ គ.ជ.ប.ជ ចំនួន០២វគ្គ លើគោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តត្បូងឃ្មុំ និងកំពង់ធំ អ្នកចូលរួមចំនួន ១១៨នាក់ ស្រី៤៦នាក់។<br>- បានចូលរួមសិក្ខាសាលាលើប្រព័ន្ធគ្រប់គ្រងទិន្នន័យ(CPIMS)ចំនួន០៣លើក និងសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងនៃការវិភាគស្ថានភាពដំបូង ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា ០១លើក។ |

| | |
|---|---|
| | - បានចូលរួមសិក្ខាសាលាលើប្រព័ន្ធគ្រប់គ្រងទិន្នន័យ(CPIMS)ចំនួន០៣លើក និងសិក្ខាសាលាពិគ្រោះយោបល់លើសេចក្ដីព្រាងនៃការវិភាគស្ថានភាពជំបូង ស្ដីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា ០១លើក។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៣៩លើក អ្នកចូលរួមសរុបចំនួន ១.៥១១នាក់ (ស្ត្រី ៧៨៧នាក់)** | |
| **ខេត្តកំពត** | - លេខាធិការដ្ឋាន គ ជ.ប.ខ.បានប្រជុំប្រចាំត្រីមាសទី២ ចំនួន ០១លើក។ |
| **ខេត្តកោះកុង** | **លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត ៖**<br>- បានជួបប្រជុំពិភាក្សាការងារមួយចំនួនពាក់ព័ន្ធនឹងការទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស នៅចក្រទ្វារព្រំដែនអន្តរជាតិចាំយាម ជាមួយរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដឹកនាំដោយអភិបាលខេត្ត អ្នកចូលរួមចំនួន ១៨នាក់ (ស្ត្រី ០៦នាក់)។<br>- បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសទី២ និងឆមាសទី១ ឆ្នាំ២០១៩ អ្នកចូលរួមចំនួន ២២នាក់ (ស្រី ០៧នាក់)។<br>- បានចូលរួមវគ្គបណ្ដុះបណ្ដាលគ្រូបង្គោលថ្នាក់តំបន់ស្ដីពី សកម្មភាពថ្នាក់ភូមិដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស នៅខេត្តតាកែវ អ្នកចូលរួម ៤២នាក់(ស្ត្រី ៣៩នាក់)។ |
| **ខេត្តកណ្ដាល** | - ក្រុមការងារក្រុង-ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែ ចំនួន ១៣លើក អ្នកចូលរួមសរុប ៣៨៧នាក់(ស្ត្រី២២នាក់)។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំកិច្ចប្រជុំពង្រឹងសមត្ថភាព ចំនួន ០២លើក អ្នកចូលរួមសរុប ៣៩នាក់(ស្ត្រី ០៩នាក់)។ |
| **ខេត្តកំពង់ធំ** | - បានប្រជុំ លេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត ប្រចាំត្រីមាសទី២ ចំនួន០១លើក អ្នកចូលរួម ៣១នាក់(ស្ត្រី ១៣នាក់)។<br>- បានចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្រប ដែលរៀបចំដោយ គ.ជ.ប.ជ នៅថ្ងៃទី១១-១៣ ខែមិថុនា ឆ្នាំ២០១៩ អ្នកចូលរួម ៥១នាក់។<br>- បានចូលរួមសិក្ខាសាលាស្ដីពី កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ ក្នុងការស៊ើបអង្កេតបទល្មើសផ្លូវភេទលើកុមារ ដែល ប្រព្រឹត្តដោយជនបរទេស នៅភោជនីយដ្ឋានទន្លេបាសាក់១ ភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩។ |
| **ខេត្តកំពង់ឆ្នាំង** | - លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យការងារប្រចាំខែមិថុនា ឆ្នាំ២០១៩ ដែលមានសមាសភាពក្រុមទាំង៦ និងស្រុក-ក្រុង ទាំង៨។<br>- មន្ត្រីការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន ០២នាក់ បានចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពី ការស៊ើបអង្កេតបទល្មើសរំលោភបំពានផ្លូវភេទលើកុមារ និងបទល្មើសផ្សេងទៀតពាក់ព័ន្ធនឹងកុមារ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។ |
| **ខេត្តបាត់ដំបង** | - បានចូលរួមសិក្ខាសាលាស្ដីពី យុទ្ធនាការ និងវិធានការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ នៅទីស្ដីការក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩។ |
| **ខេត្តសៀមរាប** | - លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រចាំខែ ចំនួន០១លើក អ្នកចូលរួម ៥០នាក(ស្ត្រី ២៨នាក់)។ |

| | |
|---|---|
| | - លោកវរសេនីយ៍ទោ ជា ហេង ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចូលរួមបើកវគ្គបណ្តុះបណ្តាលស្តីពី កិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត និងសុវត្ថិភាពក្នុងការប្រើប្រាស់អ៊ីនធឺណិត និងកិច្ចបង្ការការរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងសហគមន៍ ដល់ សិស្សានុសិស្ស គរុសិស្ស ក្រុមប្រឹក្សាសង្កាត់ នាយប៉ុស្តិ៍ មេភូមិ និងមគ្គុទេសទេសចរណ៍ ចំនួន០៤លើក អ្នកចូលរួមចំនួន ១៧០នាក់( ស្ត្រី ៨៧នាក់)។<br>- មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានប្រជុំថ្នាក់ដឹកនាំមន្ទីរ ការិយាល័យអប់រំក្រុង-ស្រុក និងសាលារៀន ស្តីពីវិធីទប់ស្កាត់ការជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារនៅតាមសហគមន៍ និងកន្លែងឡឥដ្ឋ ចំនួន ០១លើក មានអ្នកចូលរួម ៣៥នាក់(ស្ត្រី០៧នាក់)។ |
| **ខេត្តព្រៃវែង** | - លោកជំទាវប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការអនុវត្តអនុសញ្ញាការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងនារីភេទ ក្រោមប្រធានបទការលើកកម្ពស់សមភាពក្នុងអាពាហ៍ពិពាហ៍គ្រួសារ និងច្បាប់ពាក់ព័ន្ធ ដែលរៀបចំដោយក្រុមប្រឹក្សាជាតិដើម្បីស្ត្រី។ |
| **ខេត្តព្រះវិហារ** | - បានចូលរួមកិច្ចប្រជុំស្តីពី យុត្តិធម៌អនីតិជន និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលរៀបចំដោយស្ថាប័នតុលាការខេត្តព្រះវិហារ សហការជាមួយអង្គការចាប់ដៃ អ្នកចូលរួមចំនួន ១៩នាក់( ស្ត្រី ០៤នាក់)។ |
| **ខេត្តស្ទឹងត្រែង** | - ស្នងការដ្ឋាននគរបាលខេត្ត បានចាត់មន្ត្រីជំនាញ០២រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការស៊ើបអង្កេតបទល្មើសរំលោភបំពានផ្លូវភេទលើកុមារ និងបទល្មើសផ្សេងទៀតពាក់ព័ន្ធនឹងកុមារ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។ |
| **ខេត្តស្វាយរៀង** | - លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំពិភាក្សាការងារទាក់ទងការទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស នៅច្រកទ្វារអន្តរជាតិបាវិត អ្នកចូលរួម ១០នាក់( ស្ត្រី ០៧នាក់)។<br>- សហការជាមួយអង្គការឆាលហ្វាន់កម្ពុជាចំនួន០២លើក រៀបចំកិច្ចប្រជុំពិគ្រោះយោបល់អំពីសេចក្តីព្រាងខិត្តប័ណ្ណ អប់រំផ្សព្វផ្សាយការធ្វើចំណាកស្រុក និងការជួញដូរកុមារ និងកិច្ចប្រជុំប្រចាំត្រីមាសទី៤ នៃការអនុវត្តគម្រោង សហគមន៍កុមារមេត្រីប្រឆាំងនឹងការជួញដូរកុមារ និងការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព មានអ្នកចូលរួមសរុប ៦៩នាក់( ស្ត្រី ២៨នាក់)។<br>- អង្គការឆាលហ្វាន និងអង្គការ CCPCR បានបង្វឹកពីរបៀបប្រឹក្សាយោបល់ដល់អ្នកសម្របសម្រួលមណ្ឌលសហគមន៍ឃុំក្រសាំង និងអណ្តូងត្របែក និងចុះប្រឹក្សាយោបល់ដល់គ្រួសារដែលប្រឈម និងងាយរងគ្រោះដោយការធ្វើចំណាកស្រុក និងបានផ្តល់សេវាប្រឹក្សាយោបល់នៅក្នុងសហគមន៍ដល់យុវជនស្ម័គ្រចិត្ត សិស្ស គ្រួសារដែលមានបំណងស្វែងយល់ស្តីពីបញ្ហាប្រឈមងាយរងគ្រោះដោយការធ្វើចំណាកស្រុក ការរំលោភបំពាន ការកេងប្រវ័ញ្ច និងកិច្ចការពារកុមារ ចំនួន០២លើក អ្នកចូលរួម ៥៦៨នាក់( ស្ត្រី ៣២៨នាក់)។ |